ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ ភ្នំបាក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ



Media from www.moj.gov.kh resource from www.ocm.gov.kh

- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .–**

ត្រូវបានបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ ភ្នំបាក់ ដែលមានផ្ទៃដីទំហំ ៣៦(សាមសិបប្រាំមួយ)ហិចតា ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះនិងមាននិយាមកា( Datum:WGS1984 ) ដូចខាងក្រោម៖

**និយាមការគោល**

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 276197 | 1503580 | 16 | 277235 | 1503514 | 31 | 276663 | 1503721 |
| 2 | 276210 | 1503585 | 17 | 277125 | 1503571 | 32 | 276629 | 1503740 |
| 3 | 276235 | 1503555 | 18 | 277244 | 1503729 | 33 | 276598 | 1503793 |
| 4 | 276201 | 1503532 | 19 | 277358 | 1503805 | 34 | 276538 | 1503827 |
| 5 | 276359 | 1503340 | 20 | 277388 | 1503866 | 35 | 276458 | 1503839 |
| 6 | 276553 | 1503500 | 21 | 277394 | 1503922 | 36 | 276380 | 1503835 |
| 7 | 276594 | 1503489 | 22 | 277348 | 1503932 | 37 | 276347 | 1503815 |
| 8 | 276755 | 1503490 | 23 | 277302 | 1503908 | 38 | 276322 | 1503803 |
| 9 | 276755 | 1503480 | 24 | 277267 | 1503901 | 39 | 276299 | 1503839 |
| 10 | 276836 | 1503481 | 25 | 277192 | 1503864 | 40 | 276214 | 1503758 |
| 11 | 276897 | 1503504 | 26 | 277137 | 1503857 | 41 | 276219 | 1503748 |
| 12 | 276945 | 1503534 | 27 | 276937 | 1503747 | 42 | 276187 | 1503687 |
| 13 | 276973 | 1503508 | 28 | 276869 | 1503787 | 43 | 276184 | 1503637 |
| 14 | 277025 | 1503458 | 29 | 276736 | 1503788 | 44 | 276197 | 1503580 |
| 15 | 277117 | 1503453 | 30 | 276685 | 1503734 | | | |

**មាត្រា២ .–**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់នេះ
- ការពារសោភណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិនៃតំបន់នេះសម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិនិងវប្បធម៌សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារនិងការអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់។ ល/

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំនិងគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ ភ្នំបាក់ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តបន្ទាយមានជ័យ និងកងកម្លាំងប្រដាប់អាវុធមានសមត្ថកិច្ច ដើម្បីធានាដល់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពស្របតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៤ កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



Media from www.moj.gov.kh resource from www.ocm.gov.kh

10/05/2021

# ផែនទី តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំបាក់

ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ផ្ទៃដីទំហំ ៣៦ហិចតា

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខៈ..........៧៤១......អនក្រ.បក ចុះថ្ងៃទី២៥ខែ១៧ឆ្នាំ...ឆ្នាំ២០២០







| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 276197 | 1503580 | 23 | 277302 | 1503908 |
| 2 | 276210 | 1503585 | 24 | 277267 | 1503901 |
| 3 | 276235 | 1503555 | 25 | 277192 | 1503864 |
| 4 | 276201 | 1503532 | 26 | 277137 | 1503857 |
| 5 | 276359 | 1503340 | 27 | 276937 | 1503747 |
| 6 | 276553 | 1503500 | 28 | 276869 | 1503787 |
| 7 | 276594 | 1503489 | 29 | 276736 | 1503788 |
| 8 | 276664 | 1503490 | 30 | 276685 | 1503734 |
| 9 | 276755 | 1503480 | 31 | 276663 | 1503721 |
| 10 | 276836 | 1503481 | 32 | 276629 | 1503740 |
| 11 | 276897 | 1503504 | 33 | 276598 | 1503793 |
| 12 | 276945 | 1503534 | 34 | 276538 | 1503827 |
| 13 | 276973 | 1503508 | 35 | 276458 | 1503839 |
| 14 | 277025 | 1503458 | 36 | 276380 | 1503835 |
| 15 | 277117 | 1503453 | 37 | 276347 | 1503815 |
| 16 | 277235 | 1503514 | 38 | 276322 | 1503803 |
| 17 | 277125 | 1503571 | 39 | 276299 | 1503839 |
| 18 | 277244 | 1503729 | 40 | 276214 | 1503758 |
| 19 | 277358 | 1503805 | 41 | 276219 | 1503748 |
| 20 | 277388 | 1503866 | 42 | 276187 | 1503687 |
| 21 | 277394 | 1503922 | 43 | 276184 | 1503637 |
| 22 | 277348 | 1503932 | 44 | 276197 | 1503580 |

**ប្រភពទិន្នន័យ**

ចំណុចនិយាមកា និងព្រំប្រទល់តំបន់បេតិកភណ្ឌធម្មជាតិ: មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ

ព្រំប្រទល់រដ្ឋបាល: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

Map Coordinate System:
Unit: meter
System: UTM, Zone 48
Datum: WGS 1984

មាត្រដ្ឋាន ១:៦ ០០០



resource from www.ocm.gov.kh